**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១០៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ត្រួតពិនិត្យផលិតផលថ្នាំជក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៤ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

ត្រូវបានបង្កើតគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ដែលសរសេរជាអក្សរកាត់ថា "**គ.ត.ផ.ថ.**" ដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ដើម្បីអប់រំនិងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់។

## ជំពូកទី២

## សមាសភាព

**មាត្រា២ ._**

គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ "**គ.ត.ផ.ថ.**" មានសមាសភាពដូចខាងក្រោម៖

១. រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធាន
២. រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប អនុប្រធានអចិន្ត្រៃយ៍
៣. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប អនុប្រធាន
៤. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប អនុប្រធាន
៥. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប អនុប្រធាន
៦. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
៧. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប សមាជិក
៨. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
៩. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប សមាជិក
១០. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប សមាជិក
១១. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
១២. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ១រូប សមាជិក
១៣. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
១៤. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
១៥. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប សមាជិក
១៦. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
១៧. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប សមាជិក
១៨. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងផែនការ ១រូប សមាជិក
១៩. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូបសមាជិក
២០. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប សមាជិក
២១. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ១រូបសមាជិក
២២. តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ១រូប សមាជិក
២៣. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ១រូប សមាជិក

២៤. ប្រធានមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព ១រូប សមាជិក និងលេខាធិការ

សមាសភាពជាក់ស្តែងរបស់ **គ.ត.ផ.ថ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

សមាជិក **គ.ត.ផ.ថ.** ជាបុគ្គលដែលមិនជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ជាមួយឧស្សាហកម្មឬក្រុមហ៊ុនផលិតផលថ្នាំជក់ មានជាអាទិ៍ សមាជិកភាគហ៊ុនឬសមាជិកទទួលផលប្រយោជន៍ពីឧស្សាហកម្មឬក្រុមហ៊ុនផលិតផលថ្នាំជក់។

## ជំពូកទី៣
## ភារកិច្ចរបស់ គ.ត.ផ.ថ.

**មាត្រា៤ .-**

គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ " **គ.ត.ផ.ថ.**" មានភារកិច្ចដូចតទៅ៖

១. ពិនិត្យនិងផ្តល់យោបល់លើគោលនយោបាយ ផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិសម្រាប់ត្រួត-ពិនិត្យផលិតផលថ្នាំជក់ ដើម្បីសុខភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

២. ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ វិសោធនកម្មច្បាប់ អនុក្រឹត្យ សារាចរ សេចក្តីណែនាំ និងបទដ្ឋាននានា ទាក់ទងនឹងការត្រួតពិនិត្យផលិតផលថ្នាំជក់។

៣. ផ្សព្វផ្សាយ អប់រំ និងចលនាការចូលរួមពីគ្រប់មជ្ឈដ្ឋានលើការត្រួតពិនិត្យផលិតផលថ្នាំជក់ និងជំរុញឲ្យមានការចូលរួមពីស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សេវាឯកជន និងសហគមន៍ ដើម្បីអនុវត្តច្បាប់ អនុក្រឹត្យ សារាចរណែនាំ និងការស្រាវជ្រាវ សម្រាប់ការត្រួតពិនិត្យផលិតផលថ្នាំជក់ឲ្យមានប្រសិទ្ធភាព។

៤. សហការ តាមដាន និងពង្រឹងការអនុវត្តបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធ និងវាយតម្លៃផែនការ សកម្មភាព និងយុទ្ធសាស្ត្រជាតិស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

៥. សម្របសម្រួលការអង្កេតស្រាវជ្រាវលើការប្រើប្រាស់ផលិតផលថ្នាំជក់និងផលវិបាកនៃការប្រើប្រាស់ផលិតផលថ្នាំជក់លើសុខភាពនិងសេដ្ឋកិច្ច។

៦. សម្របសម្រួលលើការសិក្សាវាយតម្លៃលើបរិមាណផលិតផលថ្នាំជក់ដែលនាំចេញ នាំចូល តម្លៃ និងការប្រើប្រាស់ថ្នាំជក់ វត្ថុជាតុដើម គ្រឿងម៉ាស៊ីន ប្រាក់ចំណូល ការដាំដំណាំថ្នាំជក់ និងព័ត៌មានផ្សេងៗទៀត។

៧. បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

**គ.ត.ផ.ថ.** មានមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាពនៃក្រសួងសុខាភិបាលជាលេខាធិការដ្ឋាន ដែលមានភារកិច្ចដូចតទៅ៖

១. រៀបចំនិងធ្វើរបាយការណ៍កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់។

២. ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នដែលមានតំណាងជាសមាជិក **គ.ត.ផ.ថ.**

៣. បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ **គ.ត.ផ.ថ.**។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ត.ផ.ថ.

**មាត្រា៦ .-**

**គ.ត.ផ.ថ.** ត្រូវធ្វើការប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន និងអាចកោះប្រជុំវិសាមញ្ញតាមការចាំបាច់តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានមានធុរៈ ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៧ .-**

**គ.ត.ផ.ថ.** ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងផ្នែកឯកជនដែលគ្មានទំនាក់ទំនងជាមួយឧស្សាហកម្មថ្នាំជក់ ដើម្បីជំរុញកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់ផលិតផលថ្នាំជក់។

**មាត្រា៨ .-**

**គ.ត.ផ.ថ.** មានសិទ្ធិប្រើត្រារបស់ក្រសួងសុខាភិបាល ដើម្បីដំណើរការការងាររបស់ខ្លួន។

**មាត្រា៩ .-**

**គ.ត.ផ.ថ.** ត្រូវបង្កើតអនុគណៈកម្មាធិការដែលសរសេរជាអក្សរកាត់ថា "**អ.គ.ត.ផ.ថ.**" នៅតាមរាជធានីខេត្តតាមការចាំបាច់ ដើម្បីជួយបំពេញការងាររបស់ខ្លួន។

**មាត្រា១០ .-**

សមាសភាពនិងតួនាទីរបស់អនុគណៈកម្មាធិការនៅតាមរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ត.ផ.ថ.**។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១១ .-**

**គ.ត.ផ.ថ.** ត្រូវមានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិសម្រាប់ដំណើរការ។

**គ.ត.ផ.ថ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីដៃគូអភិវឌ្ឍនិងប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា១២ .-**

ចំពោះអនុគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ដែលត្រូវបង្កើតនៅតាមរាជធានី ខេត្ត មានប្រភពធនធានដែលផ្គត់ផ្គង់ដោយកញ្ចប់ថវិកាជាតិរបស់រាជធានី ខេត្ត សាមី និងមូលនិធិដែលបានមកពីដៃគូអភិវឌ្ឍនិងប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ